# មាតិកា

## ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ០៨-៦-២០០០ | - ព្រះរាជក្រឹត្យ នស/រកត/០៦០០/១០៤ បំពាក់មេដាយការពារជាតិ ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ | ៩៦៨ |
| ០៨-៦-២០០០ | - ព្រះរាជក្រឹត្យ នស/រកត/០៦០០/១០៥ បំពាក់មេដាយសេនាជ័យសិទ្ធ ជូនដល់ឥស្សរជនជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ | ៩៧៣ |
| ០៨-៦-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/០៦០០/១០៦ តែងតាំងលោក ឈឹង ថៃហ៊្វៀយ ជាឧកញ៉ា | ៩៧៤ |
| ០៨-៦-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/០៦០០/១០៧ តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រី ជូនវរសេនីយ៍ឯក សៅ វ៉ានី | ៩៧៤ |


## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ៣១ អនក្រ.បក ស្តីពីការបង្កើតស្រុកគាស់ក្រឡ ចំណុះខេត្តបាត់ដំបង | ៩៧៥ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ៣២ អនក្រ.បក ស្តីពីវិសោធនកម្មមាត្រា ១៤ និង ១៥ នៃអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ | ៩៧៦ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ៣៣ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មការជាតិសំរាប់រៀបចំកិច្ចប្រឡងចូលរៀនតាមសាកលវិទ្យាល័យនិងគ្រឹះស្ថានឧត្តមសិក្សានានា នៃព្រះរាជាណាចក្រកម្ពុជា | ៩៧៩ |
| ០២-៦-២០០០ | - អនុក្រឹត្យលេខ១៩៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយទាហាន | ៩៨១ |
| ០៥-៦-២០០០ | - អនុក្រឹត្យ លេខ ១៩៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៩៨២ |
| ០៥-៦-២០០០ | - អនុក្រឹត្យ លេខ ១៩៧ អនក្រ.តត ស្តីពីការតែង... ន្ត្រីរាជការ | ៩៨៣ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ១៩៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៩៨៤ |

| | | |
|---|---|---|
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ១៩៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៩៨៥ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ២០០ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ៩៨៦ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ២០១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៩៨៧ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ២០២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៩៨៨ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ២០៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៩៨៩ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ២០៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៩៩០ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ២០៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៩៩១ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ២០៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៩៩២ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ២០៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៩៩៣ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ២០៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៩៩៤ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ២០៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៩៩៥ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ២១០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៩៩៦ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ២១១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៩៩៧ |
| ០៦-៦-២០០០ | - អនុក្រឹត្យ លេខ ២១២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៩៩៨ |
| ០៨-៦-២០០០ | - អនុក្រឹត្យ លេខ ២១៣ អនក្រ.តត ស្តីពីការបំពាក់ឋានន្តរសក្តិនាយនគរបាលជាតិ | ៩៩៩ |
| ០៨-៦-២០០០ | - អនុក្រឹត្យ លេខ ២១៤ អនក្រ.តត ស្តីពីកាផ្ទេរភារកិច្ច និង តែងតាំងមុខតំណែងនាយនគរបាលជាតិ | ១០០០ |


## ២-សេចក្តីសំរេច


| | | |
|---|---|---|
| ០៦-៦-២០០០ | - សេចក្តីសំរេចលេខ ៣៧ សសរ ស្តីពីការផ្ទេរសិទ្ធិនៃរាជរដ្ឋាភិបាល | ១០០១ |
| ០៧-៦-២០០០ | - សេចក្តីសំរេចលេខ ៣៨ សសរ ស្តីពីការ តែងតាំងបន្ថែមសមាជិកគណៈកម្មការដោះស្រាយបាតុភាពបញ្ហាដីធ្លី នៅតាមបណ្តាខេត្ត-ក្រុងទូទាំងប្រទេស | ១០០២ |
| ០៨-៦-២០០០ | - សេចក្តីសំរេចលេខ ៣៩ សសរ. ស្តីពីការបង្កើតក្រុមការងារជួសជុល សាងសង់ផ្លូវទៅកាន់មជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញ កម្ពុជា-ថៃ ពូនភ្នំ | ១០០៣ |

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

## ព្រះរាជក្រឹត្យ នស/រកត/០៦០០/១០៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស**

**ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

-បានទ្រង់ទតរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់ទតព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់ទតព្រះរាជក្រមលេខ០២នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់ទតព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់ទតសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ .-ត្រូវបានប៉ាក់មេដាយការពារជាតិ ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន១០រូប ក្នុងមួយរូបៗ គឺសំរិទ្ធ០២គ្រឿង ប្រាក់០២គ្រឿង និងមាស ០១គ្រឿង ដូចមានរាយនាមខាងក្រោម :

១-ឧត្តមសេនីយ៍ឯក **ឯម សំអាន** អត្តលេខ ០០១ រដ្ឋលេខាធិការ

២-ឧត្តមសេនីយ៍ឯក **គៀង វ៉ាង** អត្តលេខ ០០២ រដ្ឋលេខាធិការ

៣-ឧត្តមសេនីយ៍ឯក **ហុក ឡុងឌី** អត្តលេខ ០០៤ អគ្គនាយក នៃ អគ្គនាយកដ្ឋាននគរបាលជាតិ

៤-ឧត្តមសេនីយ៍ឯក **យ៉េង ម៉ារឌី** អត្តលេខ ០០៥ អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល

៥-ឧត្តមសេនីយ៍ឯក សូរ ផន អត្តលេខ ០០៦ អគ្គនាយករងទី១ នៃ អគ្គនាយកដ្ឋាននគរបាលជាតិ

៦-ឧត្តមសេនីយ៍ឯក ឡុយ សុផាត អត្តលេខ ០០៧ អភិបាលខេត្តព្រះ

៧-ឧត្តមសេនីយ៍ទោ តេង សាវង្ស អត្តលេខ ០០១១ អគ្គនាយករង នៃ អគ្គនាយកដ្ឋាននគរបាលជាតិ

៨-ឧត្តមសេនីយ៍ទោ គីង សំណាង អត្តលេខ ០០១២ អគ្គនាយករង នៃ អគ្គនាយកដ្ឋាននគរបាលជាតិ

៩-ឧត្តមសេនីយ៍ទោ រស់ សារុំ អត្តលេខ ០០១៥ អគ្គាធិការរង នៃ អគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល

១០-ឧត្តមសេនីយ៍ទោ យូ ស៊ុនឡុង អត្តលេខ ០០១៨ ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី-អគ្គលេខាធិការរងនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ

**មាត្រា ២ .-** ត្រូវបានបំពាក់មេដាយការពារជាតិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន៨រូប ក្នុងមួយរូបៗ សរីទ្ធ០២គ្រឿង ប្រាក់០១គ្រឿង និងមាស ០២គ្រឿង ដូចមានរាយនាមខាងក្រោម :

១-ឧត្តមសេនីយ៍ទោ ឈឹម ជួន អត្តលេខ ០០១៦ អភិបាលរងទី១ ខេត្តកំពត

២-ឧត្តមសេនីយ៍ទោ គឹម អាន់ អត្តលេខ ០០១៩ ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន

៣-ឧត្តមសេនីយ៍ទោ លុយ សាវុន អត្តលេខ ០០១៧ អតីតប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌

៤-ឧត្តមសេនីយ៍ទោ ណុប ស៊ីណូ អត្តលេខ ០០១៥ ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ

៥-ឧត្តមសេនីយ៍ទោ នេត សាវឿន អត្តលេខ ០០៦៦ ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌

៦-ឧត្តមសេនីយ៍ត្រី ហ៊ិល សក្ដា អត្តលេខ ០០២៥ អនុប្រធានទី១ នាយកដ្ឋានកណ្តាលមធ្យោបាយ

៧-ឧត្តមសេនីយ៍ត្រី គឹម សំណាង អត្តលេខ ០០៦១ អនុប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ

៨-ឧត្តមសេនីយ៍ត្រី ណុម ណាត អត្តលេខ ០០២៦ អនុប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ

| | | | |
|---|---|---|---|
| ៩-ឧត្តមសេនីយ៍ត្រី | លន់ ណេត | អត្តលេខ ០០៥៤ | អនុប្រធាននាយកដ្ឋានកណ្តាល សន្តិសុខ |
| ១០-ឧត្តមសេនីយ៍ត្រី | សួន វ័ត្ថសារ៉ាយ | អត្តលេខ ០០២៩ | អនុប្រធាននាយកដ្ឋានកណ្តាល សន្តិសុខ |
| ១១-ឧត្តមសេនីយ៍ត្រី | ហ៊ីង ឆន | អត្តលេខ ០០៣០ | អនុប្រធានទី១នាយកដ្ឋានកណ្តាល នគរបាលព្រំដែន |
| ១២-ឧត្តមសេនីយ៍ត្រី | ម៉ែន អ៊ិន | អត្តលេខ ០០៤១ | អនុប្រធាននាយកដ្ឋានកណ្តាល នគរបាលព្រំដែន |
| ១៣-ឧត្តមសេនីយ៍ត្រី | សឹទ្ធ គិរី | អត្តលេខ ០០២៨ | អនុប្រធាននាយកដ្ឋានកណ្តាល នគរបាលព្រំដែន |
| ១៤-ឧត្តមសេនីយ៍ត្រី | ថន អ៊ិម | អត្តលេខ ០០៣២ | អនុប្រធាននាយកដ្ឋានកណ្តាល នគរបាលយុត្តិធម៌ |
| ១៥-ឧត្តមសេនីយ៍ត្រី | ច័ន្ទ រិទ្ធី | អត្តលេខ ០០៣៣ | អនុប្រធាននាយកដ្ឋានកណ្តាល នគរបាលយុត្តិធម៌ |
| ១៦-ឧត្តមសេនីយ៍ត្រី | យុន ឈុន្លី | អត្តលេខ ០០២២ | អនុប្រធានទី១នាយកដ្ឋានកណ្តាល សណ្តាប់ធ្នាប់សាធារណៈ |
| ១៧-ឧត្តមសេនីយ៍ត្រី | យិន ស្រ៊ាង | អត្តលេខ ០០៤០ | អនុប្រធាននាយកដ្ឋានកណ្តាល សណ្តាប់ធ្នាប់សាធារណៈ |
| ១៨-ឧត្តមសេនីយ៍ត្រី | រស់ វណ្ណារ៉ា | អត្តលេខ ០០៣១ | អនុប្រធាននាយកដ្ឋានកណ្តាល សណ្តាប់ធ្នាប់សាធារណៈ |
| ១៩-ឧត្តមសេនីយ៍ត្រី | ម៉ៅ ម៉ុនណារិន | អត្តលេខ ០០៣៦ | ប្រធាននាយកដ្ឋានបុគ្គលិក |
| ២០-ឧត្តមសេនីយ៍ត្រី | ចក់ ឡេង | អត្តលេខ ០០៤៥ | ប្រធាននាយកដ្ឋានភស្តុភារ និង សំភារៈបច្ចេកទេស |
| ២១-ឧត្តមសេនីយ៍ត្រី | ហេង ហាក់ | អត្តលេខ ០០៦៣ | នាយករងខុទ្ទកាល័យ |
| ២២-ឧត្តមសេនីយ៍ត្រី | ម៉ៅ ចន្ទតារា | អត្តលេខ ០០២៣ | ប្រធានសេនាធិការដ្ឋាន |
| ២៣-ឧត្តមសេនីយ៍ត្រី | គន្ធ សំអឿន | អត្តលេខ ០០៥២ | ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម |
| ២៤-ឧត្តមសេនីយ៍ត្រី | ចាន់ អ៊ិន | អត្តលេខ ០០២៤ | ប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក |
| ២៥-ឧត្តមសេនីយ៍ត្រី | គិត លឹមហៃ | អត្តលេខ ០០៣៨ | ប្រធាននាយកដ្ឋានបច្ចេកទេសព្រំដែន |
| ២៦-ឧត្តមសេនីយ៍ត្រី | ឃុន សារឿន | អត្តលេខ ០០៤៤ | ប្រធាននាយកដ្ឋានសន្តិសុខសង្គម |
| ២៧-ឧត្តមសេនីយ៍ត្រី | អ៊ុក គឹមលេខ | អត្តលេខ ០០៣៤ | ប្រធាននាយកដ្ឋាននគរបាលរដ្ឋបាល |

២៨-ឧត្តមសេនីយ៍ត្រី ហៅ ឫទ្ធីសក្តិ អត្តលេខ ០០៤៧ ប្រធាននាយកដ្ឋាននគរបាលព្រំដែន
២៩-ឧត្តមសេនីយ៍ត្រី ថោង លីម អត្តលេខ ០០៤៨ ប្រធានមន្ទីរប្រឆាំងគ្រឿងញៀន
៣០-ឧត្តមសេនីយ៍ត្រី សុខ ផល អត្តលេខ ០០៥១ ប្រធាននាយកដ្ឋានព័ត៌មានទូទៅ
៣១-ឧត្តមសេនីយ៍ត្រី ស៊ឹម សុផល អត្តលេខ ០០៤៣ ប្រធាននាយកដ្ឋានអង្គរក្ស
៣២-ឧត្តមសេនីយ៍ត្រី ឌុល គឿន អត្តលេខ ០០២៧ ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៣៣-ឧត្តមសេនីយ៍ត្រី គួយ យ៉ារី អត្តលេខ ០០៥៧ ប្រធាននាយកដ្ឋានវិទ្យុទាក់ទង
៣៤-ឧត្តមសេនីយ៍ត្រី អ៊ុក សារ៉ូត អត្តលេខ ០០៥៨ ប្រធាននាយកដ្ឋានបំប្លែងអក្សរ
៣៥-ឧត្តមសេនីយ៍ត្រី អ៊ុន ឈន អត្តលេខ ០០៥៩ ប្រធាននាយកដ្ឋានផ្សព្វផ្សាយអប់រំ
៣៦-ឧត្តមសេនីយ៍ត្រី ពត គ្រួច អត្តលេខ ០០៣៥ ប្រធានអធិការដ្ឋានកិច្ចការនគរបាល
៣៧-ឧត្តមសេនីយ៍ត្រី ខៀវ សុគ៌ត អត្តលេខ ០០៧២ នាយករងខុទ្ទកាល័យ
៣៨-ឧត្តមសេនីយ៍ត្រី ដួង គឹមឆុន អត្តលេខ ០០៦៤ នាយករងខុទ្ទកាល័យ
៣៩-ឧត្តមសេនីយ៍ត្រី គឹម ចាន់នី អត្តលេខ ០០៦៧ ប្រធានការិយាល័យនគរបាលអន្តរជាតិ
៤០-ឧត្តមសេនីយ៍ត្រី ប្រាក់ សាឯម អត្តលេខ ០០៦៨ ប្រធានការិយាល័យទំនាក់ទំនងអន្តរជាតិ
៤១-ឧត្តមសេនីយ៍ត្រី ឆម្ល ខន អត្តលេខ ០០៧១ ប្រធាននាយកដ្ឋានគ្លាបនា
៤២-ឧត្តមសេនីយ៍ត្រី ម៉ាត់លីរុន ស្កាដាទី អត្តលេខ ០០៧០ ទីប្រឹក្សាអាជ្ញាធរជាតិប្រយុទ្ធនឹងគ្រឿងញៀន
៤៣-ឧត្តមសេនីយ៍ត្រី អៅ គឹមឈួន អត្តលេខ ០០៧៤ ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី
៤៤-ឧត្តមសេនីយ៍ត្រី រតន៍ វ៉ែន អត្តលេខ ០០៣៧ ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី
៤៥-ឧត្តមសេនីយ៍ត្រី ម៉ោយ ម៉ាន អត្តលេខ ០០៥០ ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី
៤៦-ឧត្តមសេនីយ៍ត្រី អ៊ឹម សៀ អត្តលេខ ០០៦២ ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី
៤៧-ឧត្តមសេនីយ៍ត្រី ហ៊ុយ ហឿន អត្តលេខ ០០៥៦ ប្រចាំការនៅអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ
៤៨-ឧត្តមសេនីយ៍ត្រី អ៊ិន សាម៉ុន អត្តលេខ ០០៣៩ ប្រចាំការនៅអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ
៤៩-ឧត្តមសេនីយ៍ត្រី លូ រាមីន អត្តលេខ ០០៥៣ អគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**មាត្រា ៣ .-** ត្រូវបានបំពាក់មេដាយការពារជាតិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន០២រូប ក្នុងមួយរូបៗ សរិទ្ធ០២គ្រឿង ប្រាក់០១គ្រឿង និងមាស ០១គ្រឿង ដូចមានរាយនាមខាងក្រោម :

១-ឧត្តមសេនីយ៍ត្រី ម៉ា ឈឿន អត្តលេខ ០០៨៩ ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹត្យការ

២-ឧត្តមសេនីយ៍ត្រី ទ៉ាន់ រដ្ឋា អត្តលេខ ០១៩០ ប្រធាននាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ

មាត្រា ៤ .- ត្រូវបានប្រគល់មេដាយការពារជាតិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន០៦រូប ក្នុងម្នាក់ៗ សំរិទ្ធ០១គ្រឿង ប្រាក់០២គ្រឿង និងមាស ០១គ្រឿង ដូចមានរាយនាមខាងក្រោម :

១-ឧត្តមសេនីយ៍ត្រី ម៉ូ លីដា អត្តលេខ ០០៦៩ អនុប្រធានទី១ នាយកដ្ឋានកណ្តាល នគរបាលយុត្តិធម៌

២-ឧត្តមសេនីយ៍ត្រី ហង្ស ទិបុលចន្ទ្រា អត្តលេខ ០០៨៣ អនុប្រធានទី១ នាយកដ្ឋានកណ្តាល សន្តិសុខ

៣-ឧត្តមសេនីយ៍ត្រី ម្រុត សារឿន អត្តលេខ ០១៩១ ប្រធាននាយកដ្ឋានជនបរទេស

៤-ឧត្តមសេនីយ៍ត្រី ហុក ធិន អត្តលេខ ០៣០២ ប្រធាននាយកដ្ឋាននគរបាលការពារ

៥-ឧត្តមសេនីយ៍ត្រី ចាន់ វាសនា អត្តលេខ ០២៩៦ ប្រធាននាយកដ្ឋាននគរបាលព្រំដែនទឹក

៦-ឧត្តមសេនីយ៍ត្រី សួន ឈានលី អត្តលេខ ០១០៤ ស្នងការ រងស្នងការដ្ឋាននគរបាល រាជធានីភ្នំពេញ

មាត្រា ៥ .- ត្រូវបានប្រគល់មេដាយការពារជាតិ ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន០១រូប សំរិទ្ធ០២គ្រឿង ប្រាក់០២គ្រឿង និងមាស ០១គ្រឿង មាននាមខាងក្រោម :

១-ឧត្តមសេនីយ៍ត្រី ថាវ គិមឡុង អត្តលេខ ០១៣៩ អភិបាលរងទី១ ខេត្តកំពង់ចាម

មាត្រា ៦ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៧ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

# ព្រះរាជក្រឹត្យ នស/រកត/០៦០០/១០៥

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស**
**ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**
**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ .-** ត្រូវបានប់ពាក់មេដាយ សេនាជ័យសិទ្ធ ជូនដល់ឥស្សរជនជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន០៥រូប ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជា សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

២-ឯកឧត្តម យូ ហុកគ្រី ទេសរដ្ឋមន្ត្រី និងជា សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

៣-ឯកឧត្តម ឯម សំអាន រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ

៤-ឯកឧត្តម កៀង វ៉ាង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ

៥-ឯកឧត្តម ឧត្តមសេនីយ៍ឯក ហុក ឡុងឌី អគ្គនាយក នៃអគ្គនាយកដ្ឋាននគរបាលជាតិ

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ត្រូវជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# ព្រះរាជក្រឹត្យ នស/រកត/០៦០០/១០៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ឈឹង ថៃហ៊ួយ

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# ព្រះរាជក្រឹត្យ នស/រកត/០៦០០/១០៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់ទតព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០៦ ខែ មិថុនា ឆ្នាំ ២០០០

## ត្រាស់បង្គាប់

មាត្រា ១ .- ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក សោ វិនី ប្រធាននាយកដ្ឋាន នគរបាលសេដ្ឋកិច្ច នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៣១ អនក្រ.បក

### ស្តីពី

### ការបង្កើតស្រុកគាស់ក្រឡចំណុះខេត្តបាត់ដំបង

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សម្រេច

មាត្រា ១ .- ត្រូវបានបង្កើតស្រុកគាស់ក្រឡ ដោយកាត់យកភូមិសាស្ត្រមួយចំណែកពីស្រុកមោងឫស្សី ។

មាត្រា ២ .- ស្រុកគាស់ក្រឡ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តបាត់ដំបង ។

មាត្រា ៣ .- ស្រុកគាស់ក្រឡ ត្រូវបានបង្កើតឃុំចំនួន ០៦ គឺឃុំធិបតី ឃុំគាស់ក្រឡ ឃុំហប់ ឃុំដូនបា ឃុំព្រះផុស និងឃុំឆ្នាល់មាន់ ។

មាត្រា ៤ .- ស្រុកគាស់ក្រឡ ត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាល ដូចខាងក្រោម :

-ខាងជើង ទល់នឹងស្រុកបាណន់ និង ស្រុកសង្កែ ខេត្តបាត់ដំបង ។

-ខាងត្បូង ទល់នឹងស្រុកវាលវែង ខេត្ត ពោធិ៍សាត់ ។

-ខាងកើត ទល់នឹងស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

-ខាងលិច ទល់នឹងស្រុកសំឡូត និង ស្រុកបាណន់ ខេត្តបាត់ដំបង ។

មាត្រា ៥ .- ទីតាំងសាលាស្រុកគាស់ក្រឡ ស្ថិតនៅក្នុងឃុំគាស់ក្រឡ ។

មាត្រា ៦ .- បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ៣២ អនក្រ.បក

## ស្តីពី

## វិសោធនកម្មមាត្រា ១៤ និង ១៥ នៃអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី២៧ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-ឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-ឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-ឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១០ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

-ឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-ឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.តត ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធចាត់តាំង ក្រសួងការពារជាតិ

-ឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

-ឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## សំរេច

**មាត្រា ១ .-**

មាត្រា៤ នៃអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី២៧ ខែ មិនា ឆ្នាំ ១៩៩៦ ត្រូវបានកែតម្រូវដូចតទៅ :

**មាត្រា៤ថ្មី** : យោធិនទាំង២ភេទ ដែលមានគ្រប់ល័ក្ខខ័ណ្ឌត្រូវបានទទួលរបបសោធននិវត្តន៍ជាប្រចាំខែហើយ ដូចមានចែងក្នុងមាត្រា៥ និងមាត្រា៦ ជំពូកទី១ នៃព្រះរាជក្រមលេខ០៧ ន.ស.៩៤ ចុះថ្ងៃទី

២៨ ខែ តុលា ឆ្នាំ ១៩៩៤ ។ ក្រៅពីទទួលរបបសោធននិវត្តន៍ ជាប្រចាំខែដូចដែលបានបញ្ជាក់ក្នុងប្រការ ទី១ ខាងលើ យោធិនទាំងពីរនោះ ត្រូវបានទទួលរបបអនុគ្រោះមួយចំនួនដូចខាងក្រោម :

១-អ្នកនៅក្នុងបន្ទុកដែលរដ្ឋទទួលស្គាល់ មានសិទ្ធិទទួលរបបដូចនៅពេលបំរើការងារ ។

២-ចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍ ឬវីរជនដែលមានអ្នកបើកបររថយន្តនិងកងការពារ ត្រូវបានរាជរដ្ឋាភិបាលពិនិត្យ និងដោះស្រាយជាក់ស្ដែង ។

៣-ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងអាជ្ញាធរមានសមត្ថកិច្ច មានភារកិច្ចពិនិត្យលទ្ធភាព ជួយរកការងារធ្វើអោយនិវត្តជន ឬជនបាត់បង់សមត្ថភាពការងារ ដែលនៅមានលទ្ធភាពបន្តការងារទៀត បាន ដោយផ្អែកទៅតាមសំណើ និងជំនាញរបស់សាមីខ្លួន ។

**មាត្រា ២ .-**

មាត្រា១៤ នៃអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩៦ ត្រូវបានកែតម្រូវដូចតទៅ :

**មាត្រា១៤ថ្មី** :- ជារៀងរាល់ឆ្នាំ ក្រសួងការពារជាតិ ត្រូវគ្រប់បញ្ជីឈ្មោះយោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពការងារ និងយោធិនមិនបានបំពេញលក្ខខ័ណ្ឌចូលនិវត្តន៍ ឬចូលបាត់បង់សមត្ថភាពការងារ ជូនក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ និងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ដើម្បីបំរុងថវិកាក្នុងការបើកផ្ដល់សោធននិវត្តន៍ សោធនបាត់បង់សមត្ថភាពការងារ និងយោធិនមិនបានបំពេញលក្ខខ័ណ្ឌចូលនិវត្តន៍ ឬចូលបាត់បង់សមត្ថភាពការងារ ។

-ការគ្រប់គ្រង និងបើកផ្ដល់របបសោធននិវត្តន៍ និងយោធិនបាត់បង់សមត្ថភាពការងារប្រចាំខែ និងបើករបបធានារ៉ាប់រងសង្គមនៅពេលនិវត្តជន ឬជនបាត់បង់សមត្ថភាពការងារ មានជំងឺ ឬគ្រោះថ្នាក់ និងប្រាក់ធានារ៉ាប់រងសង្គមសំរាប់គ្រួសារក្រោយមរណភាពរបស់និវត្តជន ឬ ជនបាត់បង់សមត្ថភាពការងារ ជាសមត្ថកិច្ចរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រហូតដល់ពេលបង្កើតបានបេឡាសោធន ។

-ក្រសួងការពារជាតិមានភារកិច្ចបើកប្រាក់ឧបត្ថម្ភ១លើក ជូនដល់និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងយោធិនមិនបានបំពេញលក្ខខ័ណ្ឌចូលនិវត្តន៍ ឬជនបាត់បង់សមត្ថភាពការងារ នៃកងយោធពលខេមរភូមិន្ទ ដូចមានចែងក្នុងមាត្រា៥ ចំណុចលេខ១ មាត្រា៦ មាត្រា១១ ចំណុចលេខ១ មាត្រា១៣ នៃច្បាប់ស្ដីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពល ខេមរភូមិន្ទ មុនពេលផ្ទេរទៅអោយក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។

**មាត្រា ៣ .-**

មាត្រា១៥ នៃអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី២៧ ខែ មីនា ឆ្នាំ ១៩៩៦ ត្រូវបានកែតម្រូវដូចតទៅ :

**មាត្រា១៥ថ្មី** :- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី និង

អតីតយុទ្ធជន និងអភិបាលខេត្ត-ក្រុង ទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថ និងចុះហត្ថលេខានេះតទៅ ។

មាត្រា ៤ -.

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវ ទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០០

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ហត្ថលេខា ព្រះហស្តលេខា

ទៀ បាញ់ ស៊ីសុវត្ថិ សិរីរ័ត្ន

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

***

## អនុក្រឹត្យ លេខ ៣៣ អនក្រ.បក

ស្តីពី

## ការបង្កើតគណៈកម្មការជាតិ សំរបសំរួលសាកលវិទ្យាល័យ និងគ្រឹះស្ថានឧត្តមសិក្សានានា នៃព្រះរាជាណាចក្រកម្ពុជា

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥៩៩/៨៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភា

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

មាត្រា ១ .- បង្កើតគណៈកម្មការជាតិសំរាប់រៀបសាកលវិទ្យាល័យ និងគ្រឹះស្ថានឧត្តមសិក្សានានា ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម សុខ អាន | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម ម៉ុត ចន | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា | អនុប្រធាន |
| ៣-ឯកឧត្តម អ៊ឹម សិទ្ធី | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា | អនុប្រធាន |
| ៤-ឯកឧត្តម ស៊ន សំណាង | ប្រធានរាជបណ្ឌិត្យសភាកម្ពុជា | អនុប្រធាន |
| ៥-បណ្ឌិត ខៀវ ថាវិកា | ប្រធាននាយកដ្ឋានពត៌មាន និងសការគមនាគមន៍ | លេខាធិការ |
| ៦-ឯកឧត្តម ពិត ចំណាន | សាកលវិទ្យាធិការសាកលវិទ្យាល័យភ្នំពេញ | សមាជិក |
| ៧-ឯកឧត្តម ទូ គីមឡៀរ | សាកលវិទ្យាធិការសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| ៨-ឯកឧត្តម នុយ គឿន | សាកលវិទ្យាធិការសាកលវិទ្យាល័យវិចិត្រសិល្បៈ | សមាជិក |
| ៩-ឯកឧត្តម ចាន់ ណារ៉ែត | សាកលវិទ្យាធិការសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ១០-បណ្ឌិត ហ៊ាន សាហ៊ីប | ប្រធានវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១-បណ្ឌិត ឆ សោះ | ព្រឹទ្ធបុរសមហាវិទ្យាល័យពេទ្យកោសល្យ | សមាជិក |
| ១២-លោក យត់ ខ៊ុយ | ព្រឹទ្ធបុរសរងមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច | សមាជិក |
| ១៣-លោក អ៊ុយ វ៉ាន់ថុន | ប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ១៤-ឯកឧត្តម អ៊ីវ ថុង | ប្រធានវិទ្យាស្ថានជាតិគ្រប់គ្រង | សមាជិក |
| ១៥-ឯកឧត្តម លី គឹមសុខ | នាយកសាលាភូមិន្ទរដ្ឋបាល | សមាជិក |
| ១៦-លោក មាស ម៉ែនរិទ្ធ | ប្រធានគណៈគ្រប់គ្រងមហាវិទ្យាល័យវេស្ទើន | សមាជិក |

មាត្រា ២ -. គណៈកម្មការនេះមានភារកិច្ចសំរបសំរួល ធ្វើការកែទំរង់ និងពង្រឹងប្រព័ន្ធឧត្តមសិក្សានៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើអោយសំរេចគោលដៅជាយុទ្ធសាស្ត្រ ចំនួន ៦ ដូចខាងក្រោមនេះ :

១-ការពង្រឹងប្រព័ន្ធ និងរចនាសម្ព័ន្ធឧត្តមសិក្សាតាមរយៈបទដ្ឋាននានា ដែលឆ្លើយតបនឹងតំរូវការចាំបាច់នាពេលបច្ចុប្បន្ន ។

២-ការប្រើប្រាស់អោយបានល្អប្រសើរជាអតិបរមានូវធនធានជាតិ និងអន្តរជាតិ ។

៣-ការពង្រឹងគុណភាពអប់រំ ដើម្បីផ្សារភ្ជាប់ឧត្តមសិក្សាទៅនឹងតំរូវការទីផ្សារពលកម្មអោយមានប្រសិទ្ធភាពខ្ពស់ ។

៤-ការរៀបចំកម្មវិធីឧត្តមសិក្សាអោយឆ្លើយតបនឹងតំរូវការចាំបាច់នៃការអភិវឌ្ឍន៍របស់ប្រទេស ។

៥-ការពង្រឹងភាសាជាតិ និងការទទួលស្គាល់តំលៃនៃភាសាបរទេសមួយចំនួនដែលរួមចំណែកដល់ការអភិវឌ្ឍន៍ ។

៦-ការពង្រឹងតួនាទីគ្រប់គ្រងនៃប្រព័ន្ធ និងស្ថាប័នឧត្តមសិក្សា ។

**មាត្រា៣** -.គណៈកម្មការនេះត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅរាជបណ្ឌិតសភាកម្ពុជា ដើម្បីចាត់ចែងការងារប្រចាំថ្ងៃ ។

**មាត្រា ៤** -. សមាជិកគណៈកម្មការទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**មាត្រា ៥** -. គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់រាជបណ្ឌិតសភាកម្ពុជា ។

**មាត្រា ៦** -.បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដែលមាននាមចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យ លេខ ១៩៥ អនក្រ.តត

## ស្តីពី

## ការតម្លើងឋានន្តរសក្តិនាយទាហាន

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ

-យោងតាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## សំរេច

មាត្រា ១ .- ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់វរសេនីយឯក ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម :

១-លោកវរសេនីយ៍ទោ ម៉ិច សូឡី អត្តលេខ ០០២៣៥០ អង្គរក្សការពារផ្ទាល់ កងពលតូចលេខ ៧០

២-លោកវរសេនីយ៍ទោ ឡៀង សំអឿន អត្តលេខ ០០២៣៨៣ អង្គរក្សការពារផ្ទាល់ កងពលតូចលេខ ៧០

៣-លោកវរសេនីយ៍ទោ អ៊ុង ចំណាន អត្តលេខ ០០២៣៥៤ អង្គរក្សការពារផ្ទាល់ កងពលតូចលេខ ៧០

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ១៩៦ អនក្រ.តត

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-យោងតាមសំណើរបស់ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ .- ត្រូវបានតែងតាំងលោកស្រី ឌួត មញ្ញា បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអង្គការអន្តរជាតិ និងជានាយករងខុទ្ទកាល័យរដ្ឋមន្ត្រី ជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២ .-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

បានចុះហត្ថលេខា

ហ៊ុន សែន

★★★

**អនុក្រឹត្យ លេខ ១៩៧ អនក្រ.តត**

**ស្តីពី**

**ការតែងតាំងមន្ត្រីរាជការ**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-យោងតាមសំណើរបស់ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

មាត្រា ១ .- ត្រូវបានតែងតាំងលោកស្រី ហៃ សុន្ធរិន្ទ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអង្គការប្រជុំកំពូលទី ជាប្រធាននាយកដ្ឋានអង្គការប្រជុំកំពូលទី នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២ .-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្ត អនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យ លេខ ១៩៨ អនក្រ.តត
## ស្តីពី ការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## សំរេច

មាត្រា ១ .- ត្រូវបានប្រគល់មេដាយ **មាសស្ថាបនាជាតិ** ជូនលោក HENRY REINERT ប្រធានអង្គការ "TERRE DES HOMMES-LUXEMBOURG" ដែលបានផ្តល់ថវិកាសំរាប់ជួយកសាងអាគារសិក្សា និងសមិទ្ធផលផ្សេងៗ ក្នុងវិស័យអប់រំ នៅស្រុកពញាឮ **ខេត្តកណ្តាល ចំណាយអស់ទឹកប្រាក់**សរុបចំនួន ១៥៣.០៦៧ ដុល្លារសហរដ្ឋអាមេរិក ។

